# [-ចោរ-]

****រឿងមួយដែលសរសេរចេញពីការយល់សប្តិ****

ខ្ញុំជាកូនអ្នកក្រ។ ទេវតាពិតជាបិទភ្នែកមើលមនុស្សលោកមែន គ្រួសារខ្ញុំក្រហើយ នៅធ្វើឲ្យម្តាយខ្ញុំកើតកូនម្តងពីរទៀត! គឺខ្ញុំជាកូនភ្លោះឈ្មោះសំអាន ជាបងរបស់អាសំអូន។ ពេលនេះឪពុកខ្ញុំកំពុងដេកឈឺនៅលើកន្ទេល។ ឯម្តាយខ្ញុំរកស៊ីមួយថ្ងៃកាត់មួយថ្ងៃកោរ បានព្រឹកខ្វះថ្ងៃបានថ្ងៃខ្វះល្ងាច! ឲ្យគ្រប់គ្រាន់ម្តេចបាន បើនំបញ្ចុកមួយកញ្ច្រែងតូច ចិញ្ចឹមគ្នាដល់ទៅ៤នាក់ឯណោះ។

ពេលនេះខ្ញុំរៀនថ្នាក់ទី៩ហើយ។ ថ្ងៃស្អែកខ្ញុំនឹងទៅប្រលងសិស្សពូកែនៅខេត្តសៀមរាប។ ថ្វីបើគ្រួសារយើងក្រ តែសេចក្តីល្អយើងមិនក្រទេ។ ខ្ញុំរៀនពូកែល្បីពេញម៉ាភូមិនរណាមិនដឹង! ឯសំអូនប្អូនខ្ញុំ សុភាពស្លូតបូតចេះគោរពចាស់ទុំ នរណាមិនស្គាល់ក្មេងគំរូ! តែអន់បន្តិចត្រង់ថាមិនបានចូលរៀនព្រោះវាបញ្ញាអន់តាំងពីតូច ម៉ែក៏ឲ្យឈប់មកជួយធ្វើការងារផ្ទះ។

«ថ្ងៃស្អែកនេះហើយឬ?» ខ្ញុំសួរដេញដោលខ្លួនឯងនៅក្នុងចិត្ត។ មិនមែនអរព្រោះមានមុខមាត់បានទៅប្រលងនៅខេត្តសៀមរាបនោះទេ! ហើយក៏មិនមែនភ័យព្រោះមិនទាន់បានមើលមេរៀនដែរ... តែកំពុងពិបាកចិត្ត ព្រោះសូម្បីតែលុយមួយរៀលក៏គ្មាននឹងខ្លួន! ម៉ែប្រាប់ថា ខ្ញុំអាចនឹងត្រូវបោះបង់ឱកាសនេះចោល ព្រោះសូម្បីតែគាត់ក៏ដើររកខ្ចីលុយគេ មកឲ្យខ្ញុំធ្វើសោហ៊ុយមិនបានដែរ។ កាន់តែគិតខ្ញុំកាន់តែពិបាកចិត្ត...

សំអូននោះឬ?... ពេលនេះវាប្រហែលជាកំពុងរត់លេងជាមួយមិត្តភក្តិ ឬបើមិនអ៊ីចឹងក៏ប្រលែងលេងជាមួយក្មេងៗក្បែរផ្ទះដែរ! និស្ស័យវាមួយ គឺចូលចិត្តលេងជាមួយក្មេងតូចៗណាស់ តែផ្ទុយស្រឡះពីខ្ញុំដែលឲ្យតែឃើញក្មេងពេលណា ចង់តែចាប់បោះចូលទៅក្នុងធុងសំរាម! គ្រួសារអ្នកមានៗជាច្រើននៅក្នុងភូមិទុកចិត្តប្អូនខ្ញុំណាស់ បើមានរវល់អីពេលណាតែងតែហៅវាឲ្យពរកូនដើរលេងជានិច្ច ឬបើមិនអ៊ីចឹងក៏ហៅឲ្យទៅជួយមើលនៅក្នុងផ្ទះ ចេញចូលម៉ាសេរី ដោយមិនខ្លាចបាត់បង់របស់របរអ្វីសោះ។

រឿងស្មានមិនដល់ក៏កើតឡើងនៅក្នុងព្រលប់ថ្ងៃនោះ...

ខ្ញុំកំពុងជួយម៉ែដាក់ដាំបាយ ខណៈដែលគាត់កំពុង បុកគ្រឿងទឹកសម្លនំបញ្ចុក។ ភ្លាមនោះ ស្រាប់តែឮសំឡេងហៅម៉ែយ៉ាងស្លន់ស្លោពីចម្ងាយរត់ចូលមកក្នុងផ្ទះ...

«ម៉ែអាក្អួនអើយ... ម៉ែអាក្អួន...» ម្ចាស់សំឡេងរត់មកដល់ ភ្នែកក្រហម មុខខឹង តែស្លន់ស្លោ។

«មានរឿងអីម៉ែវា?!!» ម៉ែខ្ញុំទម្លាក់អង្រែចុះពីដៃសួរ។

«អាក្អួនកូនមីងឯង លួងអាចិនកូនខ្ញុំ យកខ្សែកទៅបាត់ហើយ!»

គ្រាំងងងងង!!!

ខ្ញុំធ្លាក់ផ្ទាំង ដែលទើបតែលាងអង្ករហើយ ពីដៃខ្វាយ។ ម្ដាយខ្ញុំលើកដៃគក់ទ្រូងផូងៗ ទាំងស្លន់ស្លោស្មានមិនដល់...

«ពុទ្ធោ... អាក្អួនកូនម្ដាយ!... ទេ!... ខ្ញុំមិនជឿថាកូនខ្ញុំហ៊ានធ្វើបែបនេះទេ! វាមិនអាសូរទ្រូងម្ដាយខ្លះទេឬ?...»

«មិនឲ្យជឿយ៉ាងម៉េច បើអាចិនស្រែកយំឲ្យក្មេងៗថា បងសំអូនឆក់ខ្សែក! បងសំអូនឆក់ខ្សែកឲ្យជាប់មាត់!» ម៉ាក់អាចិនដែលជាអ្នកមានម្នាក់នៅក្នុងភូមិឲ្យហេតុផល។

«ខ្ញុំក្រមែនម៉ាក់អាចិន... តែខ្ញុំមិនឲ្យកូនធ្វើអំពើបែបនេះទេ!... ម៉ាក់អាចិនត្រូវជឿខ្ញុំណា... អាចិនវានៅតូច វាមើលមនុស្សច្រឡំទេដឹង?...» ម៉ែខ្ញុំស្រក់ទឹកភ្នែករលីងរលោង និយាយបណ្ដើរមើលមុខខ្ញុំបណ្ដើរដែលកំពុងខឹងឡើងញ័រខ្លួននឹងអាប្អូនគម្រក់នោះ។

«ខ្ញុំក៏មិនថាអីមីងដែរ... តែក្មេងវាថាបែបនេះ ឲ្យខ្ញុំធ្វើម៉េច?... ខ្ញុំទើបតែមកពីផ្សារអម្បាញ់មិញនេះឯង! ទុកអាចិនចោលនៅមុខផ្ទះ ឲ្យវាលេងជាមួយក្មេងៗដទៃទៀត ស្រាប់តែត្រលប់មកពីផ្សារវិញ ក៏ឮវាស្រែកយំប្រាប់ដូច្នេះទៅ!» ម៉ាក់អាចិនរាងអន់សំឡេងចុះបន្តិចវិញ ទឹកមុខក៏ប្រែជាស្មើធម្មតា ប្រហែលជាគាត់គិតឃើញខ្លះហើយ ថាគ្រួសារយើងយ៉ាងម៉េច...

«ចុះឥឡូវអាក្អួនវាទៅណាហើយ នាំខ្ញុំទៅមើលមើល៍ ខ្ញុំនឹងទៅសួរវាឲ្យច្បាស់!» ម៉ែខ្ញុំជូតទឹកភ្នែកចេញ តាំងចិត្តថានឹងចាត់ការរឿងនេះឲ្យជ្រះស្រឡះ។

«ឆក់ហើយ វាដែលនៅហ៎មីង?... ឮក្មេងៗថា វារត់ទៅថ្នល់បាត់ហើយ!»

ចប់សម្ដីគាត់ហើយ ស្រាប់តែមានក្មេងជំទង់ៗមួយក្រុម រត់ចូលមកក្នុងផ្ទះខ្ញុំ ក្នុងនោះមានទាំងប្អូនខ្ញុំមកជាមួយផង។

«មីងៗ នេះអាក្អួន... ខ្ញុំឃើញវានៅអង្គុយមើលទូរទស្សន៍ផ្ទះបងជា!» ក្មេងម្នាក់ក្នុងចំណោមនោះដឹកដៃប្អូនខ្ញុំមកបង្ហាញម៉ាក់អាចិន។ ខ្ញុំក្ដាប់ដៃសម្លក់ភ្នែកខ្លៃទៅកាន់អាក្អួន ទំនងថា ឯងច្បាស់ជាត្រូវអញដាល់ហើយថ្ងៃនេះ!

ម្ដាយខ្ញុំស្ទុះហោទៅចាប់ឱបប្អូនខ្ញុំផ្អឹបនឹងទ្រូង ព្រមជាមួយទឹកភ្នែកស្រក់ច្រោកៗម្ដងទៀតះ

«អាក្អួនកូនម៉ែ... កូនមានធក់ខ្សែកគេទេ កូនប្រាប់ម៉ែតាមត្រង់មើល៍កូន! ម៉ែក្រតែម៉ែមិនឲ្យកូនទៅធ្វើបែបនេះទេណា... ម៉េចក៏កូនមិនអាសូរទ្រូងម្ដាយសោះអ៊ីចឹង?...»

«ខ្ញុំអត់បានយកខ្សែកវាទេមីង... ខ្ញុំនៅអង្គុយមើលទូរទស្សន៍ផ្ទះអាជាតាំងពីថ្ងៃម្ល៉េះ បើមីងមិនជឿសួរពួកនេះទៅ វានៅមើលជាមួយខ្ញុំទាំងអស់គ្នាហ្នឹង!» ប្អូនខ្ញុំនិយាយម៉ាត់ៗប្រាប់ទៅម៉ាក់អាចិន តែខ្ញុំសង្កេតឃើញទឹកមុខវាស្លន់ស្លោតិចៗ។

«ចុះម៉េចក៏អាចិន វាថាហ្អែងជាអ្នកយក? នុ៎ះ! វានៅយំហៅបងសំអួន! បងសំអួន! ឲ្យជាប់មាត់ណ៎!» ម៉ាក់អាចិននិយាយបូញមាត់ចង្អុលទៅទិសផ្ទះគាត់។

«អាចិនវាមិនទាន់ចេះនិយាយច្បាស់ផងហ្នឹងមីង... ចេះតែថាបិបឹៗបានហៅត្រឹមតែឈ្មោះនេះឯង... ដួនកាលមកពីវាឃើញអាក្អួនទៅលេងជាមួយវាញឹកញាប់ពេក ទើបវាចាំតែឈ្មោះអានេះទៅ!» អាជាមិត្តជិតស្និទ្ធរបស់អាក្អួនឲ្យហេតុផល។ សម្ដីវាអាចយកជាការបាន ខ្ញុំក៏គិតថាអ៊ីចឹងដែរ...

«អ៊ីចឹងនាំគ្នាទៅសួរអាចិនឲ្យច្បាស់ម្ដងទៀតមើល... ទៅបញ្ជាក់វា ថាមុននេះអាក្អួននៅលេងជាមួយវាឬក៏អត់?» ម៉ែខ្ញុំជូតទឹកភ្នែកចេញ នាំម៉ាក់អាចិននិងក្មេងៗដទៃទៀត រួមទាំងប្អូនខ្ញុំដើរសំដៅទៅផ្ទះអាចិន ដែលនៅប្រហែលជា២០ម៉ែត្រពីគ្នា។

ពេលនោះ មនុស្សម្នាក្នុងភូមិចាប់ផ្ដើមផ្អើលជ្រួលច្របល់ មកមើលលាន់នៅមុខផ្ទះអាចិន។ ខ្ញុំឈរសម្លឹងពីផ្ទះខ្លួនឯងមើលឃើញដូច្នេះ ព្រោះមិនបានដើរទៅជាមួយទេ ខ្លាចការពិតត្រូវបើកចំហថាប្អូនខ្ញុំជាចោរពិតមែន ខ្ញុំច្បាស់ជាទប់ចិត្តខ្លួនឯងមិនបានឡើយ ថាត្រូវចាត់ការជាមួយវាយ៉ាងម៉េច។

ពុកខ្ញុំក្អកខេះៗនៅលើគ្រែ។ គាត់សម្រាន្តលក់យូរហើយ ទើបតែភ្ញាក់អម្បាញ់មិញនេះព្រោះឮសំឡេងមាត់ឡូឡាខ្លាំងពេក។

«មានរឿងអីក្អាន... មិញដូចជាមានមនុស្សម្នា ចូលមកក្នុងផ្ទះយើងច្រើនម្ល៉េះ?»

«អូ... អត់អីទេពុក! ក្មេងៗវារត់ប្រលែងគ្នា ចូលមកពួនលេងក្នុងផ្ទះ ខ្ញុំទើបតែដេញចេញឲ្យទៅលេងខាងក្រៅមិញនេះឯង!» ខ្ញុំកុហកគាត់... សំឡេងសន្ទនាក៏លែងមានតទៅទៀត។

ខ្ញុំក្តាប់ដៃជាប់ ដើរទៅដើរមក ចង់ទៅមើលបន្តិចអីបន្តិច។ ក្នុងចិត្តគិតថា បើប្អូនខ្ញុំជាចោរលួចយកខ្សែកគេមែន ខ្ញុំច្បាស់ជាដាល់វាឲ្យសន្លប់នៅនឹងមុខគេតែម្តង។ ខ្ញុំក៏ដឹងថាយើងក្រយើងគ្មានលុយតែពុកនិងម៉ែអប់រំយើងបានល្អណាស់តាំងពីតូចៗមក ឬមួយព្រោះវាដើរលេងជាមួយមិត្តភក្តិខិលខូចច្រើនពេក? មែនហើយ! ក្រៅពីវាមិនបានចូលរៀនហើយ វានៅមានមិត្តភក្តិដែលជាមនុស្សបាតផ្សារច្រើនណាស់។ នេះអាចជាហេតុផលមួយដែលធ្វើឲ្យវាក្លាយជាមនុស្សបែបនេះ...

រង់ចាំស្តាប់លទ្ធផលមិនបាន ទីបំផុតខ្ញុំក៏សម្រេចចិត្តដើរទៅមើល។ មនុស្សម្នាច្រើនណាស់កំពុងរោមអាចិននិងប្អូនប្រុសខ្ញុំ ដែលកំពុងនាំគ្នាធ្វើពិសោធសួរនាំ។

«បង... សំអូន... បងសំអូន...» អាចិននៅតែទន្ទេញឈ្មោះប្អូនខ្ញុំជាប់ មិននិយាយអ្វីផ្សេងសោះក្រៅពីនេះ។

«កូនខ្ញុំមិនមែនចោរទេបងប្អូន... បងប្អូនក៏ដឹងថាអាក្អូនវាជាក្មេងបែបណា?... ទោះបីខ្ញុំក្រតែខ្ញុំមិនឲ្យកូនដើរលួចយកខ្សែកគេទេ... បងប្អូនជួយគិតផង កូនខ្ញុំមិនមែនចោរទេ!»

«មែនហើយ! ម៉ាក់អាចិនអើយ... ធ្វើមើលតែមនុស្សមិនដែលស្គាល់គ្នា! អាក្អូនស្លូតសឹងអីមួយថ្ងៃៗនៅតែជាមួយអាចិន ចេញចូលតែក្នុងផ្ទះម៉ាក់អាចិនឯង បើវាចង់លួច... របស់របរក្នុងផ្ទះនោះវាយកអស់តាំងពីយូរណាស់ហើយ!» អ៊ំប្រុសម្នាក់និយាយឡើង ទាំងចង់ខឹងជំនួសគ្រួសារខ្ញុំទៀតផង។

«តែគ្រប់គ្នាក៏ឮ... ថាអាចិនវាទន្ទេញតែបងសំអូន! បងសំអូន... ជាប់មាត់បែបនេះ តើឲ្យខ្ញុំថាយ៉ាងម៉េច?» គាត់និយាយដាច់ៗ មិនសូវហ៊ានអះអាងបែបប្រាកដប្រជាដូចលើកមុន។

«ហ៊ើយ!... ក្មេងវាចេះតែថាទៅទេ... ម៉ាក់អាចិនឯងនៅមិនទាន់ស្គាល់កូនទៀត ប៉ាម៉ាក់មិនទាន់ចេះហៅផង មកចេះហៅអាក្អួនមុន នេះក៏ព្រោះវាជិតស្និទ្ធតែជាមួយអាក្អួនតាំងពីកើត ទើបវាទន្ទេញបានតែឈ្មោះនេះទៅ!» មីងម្នាក់ទៀតដែលនៅផ្ទះជាប់ម៉ាក់អាចិនបង្ហាញហេតុផល។

«មីងៗ... ម៉ាក់ខ្ញុំមកដល់ហើយ!» អាជារត់មកចូលវង់ពិភាក្សាក្ដី ដោយហៅម៉ាក់អាចិនឲ្យមើលទៅម៉ែវាដែលទើបមកដល់។

ដំបូងខ្ញុំក៏ឆ្ងល់ដូចគ្នា ថាអាជានាំម៉ែវាមកធ្វើអី។ តែក្រោយមកក៏ដឹងថា ម៉ែវានេះហើយជាសាក្សីសំខាន់ដែលអាចអះអាងបានថា តាំងពីថ្ងៃរហូតមកដល់ពេលកើតរឿងនេះ អាក្អួនប្អូនខ្ញុំគឺអង្គុយមើលទូរទស្សន៍ក្នុងផ្ទះគាត់ជាមួយក្មេងៗឯទៀត។

«ម៉ាក់អាចិនអើយ! កុំចោទគ្នាអី ខ្ញុំសុំយកមុខខ្ញុំមកធានាចុះ ថាអាក្អួនមិនបានលួងយកខ្សែកកូនឯងទេ... វានៅមើលទូរទស្សន៍ជាមួយខ្ញុំតាំងពីថ្ងៃម្ល៉េះ ហើយទាល់តែមានរឿងថាមានក្មេងឆក់ខ្សែកអាចិននេះ ទើបក្មេងៗវាផ្អើលឈប់មើលទូរទស្សន៍អស់ទៅ!» ម៉ែអាជានិយាយទាំងធ្វើមុខបែបហួសចិត្ត។

«នេះ... រឿងមិនទាន់ចប់ទេហ៎?» អ៊ំស្រីម្នាក់ផ្ទះនៅឯក្បាលថ្នល់អើតមុខឡើង «ខ្ញុំភ្លេចមកប្រាប់ព្រោះគិតថាគ្មានរឿងយល់ច្រឡំបែបនេះ... គឺពេលខ្ញុំជញ្ជូនឥវ៉ាន់មកពីលក់វិញក្នុងពេលព្រលប់ៗនោះ ខ្ញុំឃើញក្មេងម្នាក់មុខដូចអាក្អួនអ៊ីចឹង រត់ស្លន់ស្លោមកបុកកញ្ច្រែងខ្ញុំស្ទើរតែជាច់ផ្ការ ហើយរត់ហួសទៅថ្នល់ម្ខាងបាត់ ឃើញនៅក្នុងដៃដូចជាមានកាន់អីផង តែពេលនោះមិនចាប់អារម្មណ៍ បានតែស្រែកជេរវាពីក្រោយខ្នង តែមកដឹងពេលក្រោយថា អាចិនត្រូវក្មេងលួងយកខ្សែក ខ្ញុំក៏ប្រាកដក្នុងចិត្តថាពិតជាអាក្មេងម្នាក់ដែលរត់បុកខ្ញុំនោះហើយ!»

«អូ... បែបអាមួយដែលនៅឯចុងផ្សារនោះអី! អាហ្នុងមុខដូចអាក្អួនណាស់ ហើយបងប្អូនវាសុទ្ធតែមានដៃជើងទាំងអស់ហ្នឹង!» បងប្រុសម្នាក់ទៀតឲ្យហេតុផលបន្ថែម។

«មែនហើយៗ! ច្បាស់ជាអាហ្នុងហើយ... មើលតែអាវកូនខ្ញុំម៉េច ដាក់ហាលខាងក្រៅផ្ទះមួយយប់ ព្រឹកឡើងបាត់ តែទៅឃើញបងប្អូនវាពាក់ទៅវិញ! ផ្ទះហ្នុងឮថាចោរទាំងម៉ែទាំងកូនឯណោះ។»

ខ្ញុំភ្លេចប្រាប់ទៅថា ក្រៅពីខ្ញុំនិងអាក្អួនដែលជាកូនភ្លោះនឹងគ្នា ក៏មានកូនអ្នកភូមិម្នាក់ទៀត មុខមាត់ស្រដៀងៗនឹងយើងដែរ គ្រាន់តែខ្មៅជាងបន្តិចប៉ុណ្ណោះ។ អ្នកស្រុកចូលចិត្តនិយាយលេងថា មុន

នឹងយើងមកកើត អានោះវារវល់លេងផ្ទាត់កៅស៊ូកងចាញ់កូនខ្មោចដទៃទៀត ទើបមិនសុខចិត្តក៏នៅលេងតរហូតមិនបានមកកើតព្រមគ្នាជាមួយយើងទាំងពីរក្នុងពោះម្ដាយតែមួយ។

មិនយល់ដែរ... អ៊ំស្រីនោះថា ឃើញក្មេងមុខដូចអាក្លូនរត់បុកគាត់ តែហេតុអីគាត់មិនគិតថាជាខ្ញុំទៅ ព្រោះខ្ញុំនិងអាក្លូនដូចគ្នាស្ទើរតែចាប់ច្រឡំទៅហើយ? មិនមែនតែគាត់ទេ អ្នកភូមិទាំងអស់សុទ្ធតែសន្និដ្ឋានដូចៗគាត់អ៊ីចឹង ថាអាក្មេងនៅឯចុងផ្សារនោះហើយ ដែលជាចោរលួចយកខ្សែកអាចិននោះ។ នរណាទៅហ៊ានគិតហ្ន៎... បើខ្ញុំរៀនពូកែយ៉ាងនេះ! ម្យ៉ាងក្រៅពីសម្ងំមើលសៀវភៅនៅក្នុងផ្ទះ ខ្ញុំក៏មិនដែលមករត់លេងជាមួយមិត្តភក្ដិនៅក្នុងភូមិដែរ។ នេះអាចជាហេតុផលសំខាន់មួយ ដែលគ្មាននរណាហ៊ានគិតថាខ្ញុំ!

«ល្មមឈប់ចោទគ្នានៅម៉ាក់អាចិន... ក្មេងល្អបែបនេះ មិនគួរមកលាបពណ៌គ្នាសោះ! ឃើញគេក្រកុំចោទថាគេអាក្រក់ណា... អ្នកមានខ្លះមានកូនល្អមិនដល់គ្រួសារគាត់ផង! រកស៊ីតែនំបញ្ចុកមួយកញ្ជ្រែង តែចិញ្ចឹមកូនបានរៀនពូកែរហូតល្បីពេញមួយខេត្ត!»

«មែនហើយៗ... កុំចោទគ្នាអី! ក្មេងគោរពចាស់ទុំបែបនេះ ទៅចោទគ្នាខ្មាសក្មេងក្នុងភូមិណាម៉ាក់អាចិន! សួរមើលចុះ... ចាស់ៗណាមិនអាណិតស្រលាញ់អាក្លូន?»

ដោយឃើញអ្នកភូមិទាំងចាស់ទាំងក្មេង អះអាងដូចៗគ្នាបែបនេះ ម៉ាក់អាចិនក៏ព្រមសម្រួលឥរិយាបថ ហើយនិយាយសុំទោសម៉ែខ្ញុំ៖

«មីងឲ្យខ្ញុំសុំទោសណា... ខ្ញុំខឹងមួយឆាវទើបភ្លេចគិត ថាក្មេងវាធ្លាប់ល្អនឹងអាចិន ល្អនឹងខ្ញុំប៉ុណ្ណា! នេះបើគ្មានបងប្អូនជួយដឹងឮនិងតម្រែតម្រង់ទេនោះ ខ្ញុំច្បាស់ជារករឿងនឹងអាក្លូនស្លាប់ហើយ!»

«អើមិនអីទេ... មីងក៏យល់ចិត្តឯងដូចគ្នា! ណាអាចិនក៏ហៅតែឈ្មោះអាក្លូន... ទើបមានរឿងយល់ច្រឡំបែបនេះ!»

«ក្លូន... កុំខឹងមីងណា! ស្អែកមកលេងជាមួយអាចិនផង... មីងសុំទោសដែលយល់ច្រឡំ។»

«បាទ! អត់អីទេមីង... ចាំស្អែកខ្ញុំជួយជញ្ជូនឥវ៉ាន់ម៉ែហើយ ខ្ញុំនឹងមកនាំអាចិនទៅដើរលេងទៀត!» ប្អូនខ្ញុំញញឹមតែបបូរមាត់វានៅស្លាំង ទំនងជាមិនទាន់បាត់ភ័យ នឹងការចោទប្រកាន់នៅឡើយ។

ក្មេងៗនិងអ្នកភូមិ ក៏បែកគ្នាត្រលប់ទៅផ្ទះរៀងៗខ្លួនវិញ។ ប្អូនខ្ញុំអង្គុយចុះក្បែរអាចិនអង្អែលក្បាលវាតិចៗដោយក្ដីអាណិតស្រលាញ់។ មើលចុះ! វាងាកមុខមកមើលខ្ញុំភ្លឹះៗ ភ្នែកខ្មៅក្រឹបគួរឲ្យស្រលាញ់ តែគួរឲ្យសោកស្ដាយដែលខ្ញុំមិនចូលចិត្តក្មេងៗឡើយសូម្បីតែបន្តិច។

ខ្ញុំ ម៉ែ និងអាក្អួន នាំគ្នាត្រលប់មកផ្ទះវិញ យ៉ាងជូរស្ងើយក្នុងអារម្មណ៍។ អំពើល្អរបស់យើងទេវតានៅបើកភ្នែកមើលឃើញដែរតើ! ម៉ែអាចិនថែមទាំងបានឲ្យលុយខ្ញុំមួយចំនួនទៀតផង ព្រោះគាត់ដឹងថា ថ្ងៃស្អែកខ្ញុំនឹងត្រូវទៅប្រលងសិស្សពូកែនៅខេត្តសៀមរាប ដែលជាវគ្គផ្ដាច់ព្រាត់ក្នុងការជម្រុះយកសិស្សឆ្នើមប្រចាំប្រទេស។ ម៉ោងជិតដប់យប់ទើបយើងបានញ៉ាំបាយ ប្អូនខ្ញុំអង្គុយបញ្ចុកបបរពុកយ៉ាងស្ងៀមស្ងាត់ ក្រោយពីគាត់ភ្ញាក់ដឹងខ្លួនម្ដងទៀត។ ចំណែកខ្ញុំញ៉ាំបាយមិនសូវចូលសោះ មិនដឹងថាព្រោះហេតុផលអ្វីឲ្យប្រាកដ ព្រោះរឿងហេតុពីក្បាលព្រលប់ ឬព្រោះថ្ងៃស្អែកដែលត្រូវចេញដំណើរ? មិនច្បាស់... ដឹងតែថា ខ្ញុំទទួលអារម្មណ៍ភ័យៗ។

ម៉ោង១២យប់ គ្រប់គ្នាចូលដេកស្ងាត់អស់។ ពន្លឺចង្កៀងតូចមួយនៅភ្លឺផ្លុងៗក្បែរតុរៀនរបស់ខ្ញុំ។ ខ្ញុំអង្គុយស្ងាបវែមៗ ចង់ចូលដេក តែធ្មេចភ្នែកដេកមិនលក់។ បើកសៀវភៅអានត្រង់នេះបន្តិចត្រង់នោះបន្តិច តែអានមិនចូល។ ខ្ញុំទទួលអារម្មណ៍ថាខ្លួនឯងកំពុងសោប់សល់...

ខ្ញុំក្រោកដើរចេញពីតុ ប្រមូលសៀវភៅនិងសម្លៀកបំពាក់មួយចំនួន ដាក់ទៅក្នុងវ៉ាលីត្រៀមទៅប្រលងនៅថ្ងៃស្អែក។ ខ្ញុំលាត់ជើងខោមើលរបួសត្រង់កំភួនជើងខ្លួនឯង ដែលមានឈាមកកជាប់តិចៗនៅត្រង់នោះ។ មែនហើយ... ព្រោះខ្ញុំរត់បុកកញ្ច្រែងឫស្សីរបស់អ៊ំស្រីម្នាក់នោះ ទើបធ្វើឲ្យខ្ញុំមានរបួសដូច្នេះ!

ខ្ញុំស្ទាបហោប៉ៅក្រោយ លូកយករបស់ម្យ៉ាងចេញមកមើល... ខ្សែកមាសខ្សែឆ្មារតូចមួយចាំងចិញ្ចាចនឹងភ្លើងចង្កៀងឃើញយ៉ាងច្បាស់។ ខ្ញុំទើបតែភ្ញាក់ខ្លួនថា មុននេះដែលអាចិនសម្លឹងមុខខ្ញុំភ្លឹះៗ ... គឺមានតែវាម្នាក់ប៉ុណ្ណោះដែលដឹងថា នរណាជាចោរ?

អន្ទេវាសិក, ថ្ងៃព្រ.ហ, ១១មីនា២០១០